## កិច្ចប្រជុំស្តីពី
## ការពិនិត្យស្ថានភាពនៃការអនុវត្តការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧

# បទបង្ហាញស្តីពី
# "ខ្លឹមសារសង្ខេបនៃអនុក្រឹត្យលេខ១១៣ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន"

ដោយ៖ ឯកឧត្តម ចាន់ សុធា អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

1

---

## មាតិកា

១. សារបាន
២. ខ្លឹមសារសង្ខេប
៣. ចំណុចសំខាន់ៗ
៤. ជំហានបន្ទាប់

2

## ១. សារបាន

- ❖ ការដាក់ចេញអនុក្រឹត្យលេខ១១៣ (ខែសីហា ឆ្នាំ២០១៥ ) ដើម្បីផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក
- ❖ ការដាក់ចេញសារាចរអន្តរក្រសួង (ខែវិច្ឆិកា ឆ្នាំ២០១៥) ដើម្បីផ្តល់ការណែនាំសម្រាប់ការចាប់ផ្តើមអនុវត្តអនុក្រឹត្យនេះ
- ❖ សិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យ និងសារាចរអន្តរក្រសួងខាងលើ (ខែវិច្ឆិកា ឆ្នាំ២០១៥) ដោយមានអ្នកចូលរួមប្រមាណជាង៥00 នាក់ (ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់)
- ❖ ការរៀបចំបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីគាំទ្រដល់ការអនុវត្តមុខងារដែលបានផ្ទេរនេះ
- ❖ ការដាក់ចេញលិខិតបទដ្ឋានចំនួន២ដែលត្រូវផ្សព្វផ្សាយនាពេលនេះ

3

## ២. សេចក្តីសង្ខេបនៃអនុក្រឹត្យ

អនុក្រឹត្យនេះមាន៥៦មាត្រា ចែកជា៩ជំពូក៖

- ✓ ជំពូកទី១៖ គោលបំណង គោលដៅ និងវិសាលភាព ៖ធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងសំរាមទីប្រជុំជន ប្រគល់មុខងារទៅឱ្យរាជធានី ក្រុង ស្រុក មិនអនុវត្តចំពោះសំណល់ឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់
- ✓ ជំពូកទី២៖ តួនាទីរបស់ស្ថាប័នពាក់ព័ន្ធ ៖ តួនាទីក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ រដ្ឋបាលខេត្ត មន្ទីរបរិស្ថាន រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់
- ✓ ជំពូកទី៣៖ ការញែក និងវិចខ្ចប់សំរាម សំណល់រឹង ៖ វិធានការនានាដែលតម្រូវឱ្យមានការញែក ការខ្ចប់ និងការទុកដាក់សំរាមដោយម្ចាស់សំរាម
- ✓ ជំពូកទី៤៖ វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹង៖ វិធានការនានាដើម្បីទប់ស្កាត់ការបោះ ការដុត និងការធ្វើឱ្យកកស្ទះសំរាមនៅតាមទីធ្លាសាធារណៈ

4

## ២. សេចក្តីសង្ខេបនៃអនុក្រឹត្យ

- ✓ ជំពូកទី៥៖ សេវាគ្រប់គ្រងសំរាម សំណល់រឹង៖ សិទ្ធិសម្រេចនានារបស់រាជធានីក្រុង ស្រុកក្នុងការរៀបចំបង្កើតសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ✓ ជំពូកទី៦៖ វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹង៖ វិធានការនានាក្នុងការរៀបចំ គ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹង
- ✓ ជំពូកទី៧៖ ទោសបញ្ញត្តិ ៖ ប្រភេទនៃទោស ល្មើស និងកម្រិតនៃការផាកពិន័យនានា
- ✓ ជំពូកទី៨៖ អន្តរបញ្ញត្តិ៖ យន្តការនានាដែលធានាដល់ការចាប់ផ្តើមអនុវត្តការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព
- ✓ ជំពូកទី៩៖ អវសានបញ្ញត្តិ

5

## ៣. ចំណុចសំខាន់ៗ

- ☑ ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក
- ☑ រាជធានីក្រុង ស្រុកអាច ៖
  - ✓ រៀបចំ និងប្រតិបត្តិការសេវាសំរាមដោយផ្ទាល់
  - ✓ ធ្វើកិច្ចសហការសេវាសំរាមរួមគ្នាជាមួយរដ្ឋបាលដែលមានព្រំប្រទល់ជាប់គ្នា
  - ✓ ផ្តល់សិទ្ធិធ្វើសេវាសំរាមទៅឱ្យផ្នែកឯកជន
  - ✓ ផ្ទេរមុខងារមួយផ្នែក ឬទាំងស្រុងនៃការងារសេវាសំរាមទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬសហគមន៍
- ☑ ការផ្តល់សិទ្ធិធ្វើសេវាសំរាម ទៅឱ្យផ្នែកឯកជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តតាមវិធីសាស្រ្ត និងនីតិវិធីលទ្ធកម្មជាធរមាន

6

## ៣. ចំណុចសំខាន់ៗ (ត)

- ☑ ត្រូវកំណត់តម្លៃសេវាសំរាម តាមគោលការណ៍៖
  - ✓ ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
  - ✓ ធានាទៅដល់ប្រសិទ្ធិភាព គុណភាព និងនិរន្តភាពសេវា
  - ✓ ផ្អែកលើប្រភេទទីតាំង កម្រិតអាជីវកម្ម ឬប្រាក់ចំណូល ឬតាមបរិមាណសំរាមដែលបង្កើតនិងបញ្ចេញ
  - ✓ មានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន
- ☑ កំណត់នីតិវិធីប្រមូល កម្រៃសេវាសំរាម និងការទូទាត់កម្រៃសេវាសំរាមដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលក្នុងមូលដ្ឋាន
- ☑ ចំណូលដែលប្រមូលបានពីសេវាសំរាម ជាចំណូលផ្ទាល់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក
- ☑ អាចប្រើថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេង សម្រាប់គាំទ្របន្ថែមលើការចំណាយការងារសេវាសំរាមក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

7

## ៤. ជំហានបន្ទាប់

- ☑ រាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យបណ្តាកិច្ចសន្យាសេវាសំរាមដែលមានមុនអនុក្រឹត្យនេះ និងត្រូវពិភាក្សាជាមួយម្ចាស់សេវា និងភាគីពាក់ព័ន្ធ ដើម្បីកែសម្រួលកិច្ចសន្យាឱ្យមានលក្ខណៈស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ
- ☑ ក្រុមការងារបច្ចេកទេសអន្តរក្រសួងត្រូវរៀបចំផ្សព្វផ្សាយលិខិតបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ (ឧ.ការផ្សព្វផ្សាយថ្ងៃនេះ) និងចុះផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនានាដល់រាជធានី ក្រុង ស្រុក
- ☑ រាជធានីត្រូវរៀបចំធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមទៅឱ្យខណ្ឌ
- ☑ រដ្ឋបាលខេត្តត្រូវរៀបចំផ្ទេរមុខងារគ្រប់គ្រងសំរាមទៅឱ្យក្រុង ស្រុក
- ☑ រដ្ឋបាលក្រុង ស្រុកត្រូវចាប់ផ្តើមរៀបចំផែនការ និងយន្តការនានាគ្រប់គ្រងសំរាមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

8

សូមអរគុណ!

9